អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

*រាជធានីភ្នំពេញថ្ងៃទី ១២ ខែតុលា ឆ្នាំ២០១១*

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតជាតិ

នាដើមសប្តាហ៍នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រកាសអំពីការលាលែងតំណែងរបស់ខ្លួន។ ការលាលែងរបស់សហចៅក្រមអន្តរជាតិនេះគឺជារឿងមួយដែលភ្ញាក់ផ្អើលបំផុតសម្រាប់រូបខ្ញុំ។ នាពេលកន្លងមកនេះ ទំនាក់ទំនងការងាររវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងរូបខ្ញុំជាសហចៅក្រមស៊ើបអង្កេតជាតិ បានដំណើរការទៅយ៉ាងរលូនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍ច្បាប់ និងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ជាមូលដ្ឋាន បើទោះបីជាមានការចោទប្រកាន់តាមរយៈការបំផ្លើសព័ត៌មានប្រាស់ចាកពីការពិតពីមជ្ឈដ្ឋានខាងក្រៅមួយចំនួនក៏ដោយ។

ដូចដែលមានផ្សាយជូនជាប្រចាំនៅក្នុងរបាយការណ៍ប្រចាំខែរបស់អ.វ.ត.ក និងសេចក្តីប្រកាសព័ត៌មាន របស់សហចៅក្រមស៊ើបអង្កេត សហចៅក្រមទាំងពីរបាននឹងកំពុងធ្វើចំណាត់ការនីតិវិធីលើសំណុំរឿង ០០៣ និង ០០៤ ជាពិសេសកិច្ចស៊ើបសួរនៃការស្តាប់ចម្លើយសាក្សីសំខាន់ៗ និង ការចុះទៅពិនិត្យទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានធ្វើឡើងដោយឯករាជ្យ និងគ្មានឧបសគ្គរារាំង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ។ កិច្ចនីតិវិធីទាំងនេះគឺជាការអនុវត្តនូវទស្សនាទានរួមរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ពោលគឺការផ្តោតការស៊ើបសួរលើយុត្តាធិការបុគ្គល ដូចដែលមានបញ្ជាក់នៅក្នុងសេចក្តីប្រកាសព័ត៌មានរួមគ្នាចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១១ ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤ និង របាយការណ៍របស់អ.វ.ត.កប្រចាំខែកញ្ញាឆ្នាំ 20១១។

ទោះបីជាមានការព្យាយាមបំផ្លើសព័ត៌មាននៅតាមបណ្តាសារព័ត៌មានមួយចំនួនទាក់ទងទៅនឹងចំណាត់ការនីតិវិធី និង សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតជាតិនៅតែអះអាងថា ខ្លួននឹងបន្តបំពេញការងាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដោយឯករាជ្យ និងឈរលើមូលដ្ឋានច្បាប់ និងវិធានផ្ទៃក្នុងជាមូលដ្ឋាន ហើយប្រយុទ្ធប្រឆាំងទៅនឹងរាល់ការប៉ុនប៉ងជ្រៀតជ្រែកនានាពីគ្រប់មជ្ឈដ្ឋានទាំងអស់។

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:**
**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៣ ២៨៣
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh